
Fresh News
FN MEDIA CO., LTD.
GET -- on the App Store
INSTALL



FRESH NEWS PLUS
ព័ត៌មានកីឡា សិល្បៈ បច្ចេកវិទ្យា ចំណេះដឹង









ចំណេះដឹងទូទៅ៖ ប្រវត្តិសង្ខេបការបង្កើត និងអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ (ពោធិ៍ចិនតុង) ដែលនឹងត្រូវបិទនៅខែកក្កដា ឆ្នាំ២០២៥

14-05-2025 20:28

(ភ្នំពេញ)៖ អាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង ត្រូវបានប្តូរឈ្មោះទៅជាអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៣។ ដំបូងឡើយ វាត្រូវបានបង្កើតនៅក្នុងឆ្នាំ១៩២៤ អំឡុងពេលសម័យអាណាព្យាបាលបារាំង។ តាមគ្រោងទុក វានឹងត្រូវបិទដំណើរការនៅខែកក្កដា ឆ្នាំ២០២៥ ដោយផ្លាស់ប្តូរទៅអាកាសយានដ្ឋានអន្តរជាតិតេជោ។



*** គំនិតផ្តួចផ្តើមដំបូង (១៩២៤)**

វាត្រូវបានបង្កើតដោយរដ្ឋាភិបាលអាណាព្យាបាលបារាំង ជាអាកាសយានដ្ឋានតូចមួយ ឈ្មោះថា ពោធិ៍ចិនតុង នៅឆ្នាំ១៩២៤។ គោលបំណងចម្បងនៃការបង្កើតវា គឺដើម្បីបម្រើឲ្យវិស័យកងទ័ព និងរត់ឯកសារ ស្ថិតក្រោមបណ្តាញអាកាសចរណ៍ឥណ្ឌូចិនរបស់បារាំង។

*** ការប្រើប្រាស់នៅសម័យសង្គ្រាម លោកលើកទី២ និងអំឡុងពេលជប៉ុនកាន់កាប់ (១៩៤១-១៩៤៥)**

អំឡុងពេលជប៉ុនកាន់កាប់កម្ពុជា អាកាសយានដ្ឋាននេះ ត្រូវបានពង្រីកសម្រាប់បម្រើវិស័យកងទ័ព ប៉ុន្តែមិនបានសាងសង់ជាថ្មីទេ។ កងទ័ពជប៉ុនប្រើប្រាស់វា សម្រាប់បម្លាស់ទីកងទ័ព និងវិស័យឡូជីស្ទីក។

*** ការអភិវឌ្ឍក្រោយសម័យសង្គ្រាម (១៩៤៥-១៩៥៣)**

ក្រោយសង្គ្រាមលោកលើកទី២ បារាំងបានគ្រប់គ្រងឡើងវិញ និងអភិវឌ្ឍវាទៅជាអាសយានដ្ឋានស៊ីវិល។ នៅឆ្នាំ១៩៥៣ គឺក្រោយឯករាជ្យពីបារាំង សម្តេច នរោត្តម សីហនុ បានដាក់ព្រះរាជបញ្ជាឲ្យបង្កើតជើងហោះហើរថ្មីបន្ថែមទៀត និងពង្រីកអាកាសយានដ្ឋាននានាដែលមានស្រាប់។ នៅឆ្នាំនេះដែរ ពោធិ៍ចិនតុងក៏ត្រូវបានរចនាជាអាកាសយានដ្ឋានអន្តរជាតិចម្បងរបស់កម្ពុជា។

*** ទំនើបកម្ម (ទសវត្សរ៍១៩៦០ ដល់បច្ចុប្បន្ន)**

មានឯកសារសំអាងជាច្រើនថា អាកាសយានដ្ឋានពោធិ៍ចិនតុង ធ្វើទំនើបកម្មនៅឆ្នាំ១៩៥៧ និងបើកដំណើរការជាផ្លូវការនៅឆ្នាំ១៩៥៩។ នៅទសវត្សរ៍ឆ្នាំ១៩៦០ វាត្រូវបានពង្រីកដោយដាក់ផ្លូវរត់បេតុង និងចំណតយន្តហោះដឹកអ្នកដំណើរ។

ក្នុងសង្គ្រាមស៊ីវិលកម្ពុជា អាកាសយានដ្ឋានពោធិ៍ចិនតុង បានក្លាយជាកន្លែងសំខាន់សម្រាប់អាកាសដឹកជញ្ជូនសម្រាប់ផ្នែកយោធា និងមនុស្សធម៌។ ចន្លោះខែតុលា ដល់ខែធ្នូ ឆ្នាំ១៩៧៣ យន្តហោះ C-130 របស់កងទ័ពអាកាសអាមេរិក បានដឹកអង្ករ ប្រមាណ ៣ ០០០ តោន មកភ្នំពេញតាមរយៈអាកាសយានដ្ឋាននេះ។

នៅសម័យខ្មែរក្រហម អាកាសយានដ្ឋាននេះ បានក្លាយជាទីតាំងតែមួយគត់សម្រាប់ផ្គត់ផ្គង់ តម្រូវការនានានៅក្នុងរាជានីភ្នំពេញ ក្រោយពេលខ្មែរក្រហមបានកាន់កាប់បណ្តាញផ្លូវទឹក និងផ្លូវគោក នៅខែមេសា ឆ្នាំ១៩៧៥ ពោលគឺបន្ទាប់ពីការដួលរលំនៃរបបសាធារណរដ្ឋខ្មែរ វាត្រូវបានបិទស្ទើរតែទាំងស្រុងចំពោះការធ្វើដំណើរអន្តរជាតិ លើកលែងតែជើងហោះហើរមួយចំនួន ដោយផ្ទាល់ពីទីក្រុងប៉េកាំង និងព្យុងយ៉ាង។ ជើងហោះហើរទាំងនេះ មានកម្មាភិបាល ដើម្បីបណ្តុះបណ្តាលរដ្ឋាភិបាលថ្មី ក៏ដូចជាបញ្ជាវន្ត និងមន្ត្រីការទូតកម្ពុជាមួយចំនួន ដែលស្ម័គ្រចិត្តត្រឡប់មកមាតុប្រទេសវិញ។

ក្នុងឆ្នាំ១៩៩៥ រាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា បានចូលកិច្ចព្រមព្រៀងបែងចែកសិទ្ធិ ២០ឆ្នាំជាមួយ Société Concessionaire d'Aéroport (SCA) ដែលជាក្រុមហ៊ុនរួមបង្កើតរបស់បារាំង និងម៉ាឡេស៊ី ដើម្បីបំពេញបន្ថែម និងអភិវឌ្ឍអាកាសយានដ្ឋាន។ ភាគីនេះបានដឹកនាំការអភិវឌ្ឍដ៏មានន័យសំខាន់ រួមមាន ការសាងសង់ផ្លូវដើរយន្តហោះថ្មី ចំណតយន្តហោះ អាគារស្តុកទំនិញជាដើម។ ដល់ឆ្នាំ២០០២ អាកាសយានដ្ឋាននេះការអភិវឌ្ឍបន្ថែមកាន់តែទាក់ទាញទេសចរ៕













ចំណេះដឹងទូទៅ
General Knowledge
FRESHY
Honey Lemon Tea
តែទឹកឃ្មុំក្រូសស៊ី ទាំងឆ្ងាញ់ ទាំងអនាម័យ លើសពីតែជ្រក់ធម្មតា!
ទំនាក់ទំនងទិញ
081 32 1111
088 345 1445



PROMOTION
ទិញផ្ទះ ហ្វ្រីដើគ័រ
ប្រញាប់ឡើង ចំនួនមានកំណត់!
061 955 999
សុពលភាពចាប់ពីថ្ងៃនេះ
រហូតដល់ថ្ងៃទី31 ខែកក្កដា ឆ្នាំ2026
MEKONG LAND
KNN
សម្រាប់តែ
2
វិឡាឃ្លីន B
វិឡាភ្លោះ


PHNOM PENH INTERNATIONAL AIRPORT




PROMOTION
ទិញផ្ទះ ហ្វ្រីដេគ័រ
ប្រញាប់ឡើង ចំនួនមានកំណត់!
061 955 999
សុពលភាពចាប់ពីថ្ងៃនេះ
រហូតដល់ថ្ងៃទី31 ខែកក្កដា ឆ្នាំ2026
MEKONG LAND
KNN
សម្រាប់តែ
2
វីឡាឃ្លីន B
វីឡាតេ:




អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
POCHENTONG INTERNATIONAL AIRPORT


PROMOTION
ទិញផ្ទះ ហ្វ្រីដេគ័រ
ប្រញាប់ឡើង ចំនួនមានកំណត់!
061 955 999
សុពលភាពចាប់ពីថ្ងៃនេះ
រហូតដល់ថ្ងៃទី31 ខែកក្កដា ឆ្នាំ2026
MEKONG LAND
KNN
សម្រាប់តែ
2
វិឡាឃ្លីន B
វិឡាភ្លោះ